# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

### (គ.ជ.អ.ប)




# សៀវភៅទិន្នន័យក្រុងសិរីសោភ័ណ ឆ្នាំ២០០៩

## លេខកូដក្រុងៈ ១០៦ (106)

## ខេត្តបន្ទាយមានជ័យ

តុលា ២០០៩

# សៀវភៅទិន្នន័យក្រុងសិរីសោភ័ណ

# ឆ្នាំ ២០០៩

## លេខកូតក្រុងៈ ១០៦

## ខេត្តបន្ទាយមានជ័យ

# មាតិកា


**ពាក្យគ្រាត់** ..... i

**សន្ទានុក្រម** ..... iv

**បុព្វកថា** ..... ix

**សេចក្តីផ្តើម** ..... xi

**ផ្នែក ក : ភូមិសាស្ត្រ** ..... 1

**១. ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងរដ្ឋបាល** ..... 3

**២. ផែនទីធនធានធម្មជាតិ និងប្រើប្រាស់ដី** ..... 5

**៣ ផ្ទៃដី** ..... 7

*៣.១ ផ្ទៃដី (ហិចតា)* ..... 7

*៣.២ ចម្ងាយរវាងទីរួមខេត្ត ក្រុង និងសង្កាត់* ..... 7

**ផ្នែក ខ : ស្ថានភាពក្រុង** ..... 9

**១. ព័ត៌មានទូទៅ** ..... 11

*១.១ ស្ថិតិប្រជាជន* ..... 11

*១.២ ស្ថានភាពមុខរបរប្រជាជន* ..... 12

*១.៣ ទ្រព្យសម្បត្តិ* ..... 14

**២ ផ្នែកសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ** ..... 17

*២.១ ប្រភេទផ្លូវគិតជាម៉ែត្រ រយៈពេល៣ឆ្នាំកន្លង* ..... 17

*២.២ លូដោះទឹកកខ្វក់គិតជាម៉ែត្រ រយៈពេល៣ឆ្នាំកន្លង* ..... 17

*២.៣ ប្រភេទសំណង់រំដោះទឹក និងស្ពាន* ..... 17

*២.៤ សេវាកម្មនានាក្នុងក្រុង* ..... 18

*២.៥ កសិកម្ម* ..... 18

**៣ ផ្នែកសង្គមកិច្ច** ..... 31

*៣.១ ការអប់រំ* ..... 31

*៣.២ ផ្នែកសុខាភិបាល* ..... 40

*៣.៣ ទឹកស្អាតនិងអនាម័យ* ..... 41

*៣.៤ ក្រុមជនងាយរងគ្រោះ* ..... 47

*៣.៥ អន្តោប្រវេសន៍* ..... 49

៤ បរិស្ថាន និងធនធានធម្មជាតិ ..... 51

៤.១ គ្រួសារពាក់ព័ន្ធជាមួយបញ្ហាធនធានធម្មជាតិ និងបរិស្ថាន ..... 51

៤.២ ភាគរយគ្រួសារដែលជាប់ពាក់ព័ន្ធនឹងបញ្ហាធនធានធម្មជាតិតាមបណ្តាសង្កាត់ ឆ្នាំ២០០៨ ..... 51

៤.៣ ភាគរយគ្រួសារដែលប្រមូលសំរាម និងប៉ះពាល់ដោយការបំពុលបរិស្ថាន តាមបណ្តា សង្កាត់ ឆ្នាំ២០០៨52

៤.៤ ភាគរយគ្រួសារប្រើជីគីមីនិងគ្រួសារប្រើថ្នាំគីមីសម្លាប់សត្វល្អិតតាមបណ្តាសង្កាត់ ឆ្នាំ២០០៨ ..... 52

៥ រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់ ..... 53

៥.១ ការចុះសំបុត្រកំណើត រយះពេល៣ឆ្នាំកន្លង ..... 53

៥.២ ចំនួនទារកមិនទាន់បានចុះសំបុត្រកំណើតតាមសង្កាត់ឆ្នាំ២០០៨ ..... 53

៥.៣ ចំនួនករណីអសន្តិសុខដែលបានកត់ត្រា ..... 53

៥.៤ សមាមាត្រករណីអសន្តិសុខក្នុង១០០០០នាក់តាមសង្កាត់ ឆ្នាំ២០០៨ ..... 54

៥.៥ ចំនួនករណីទំនាស់ដីធ្លីដែលបានកត់ត្រាតាមបណ្តាសង្កាត់ ឆ្នាំ២០០៨ ..... 54

៦ យេនឌ័រ ..... 55

៦.១ អំពើហិង្សាក្នុងគ្រួសារដែលកត់ត្រា រយះពេល៣ឆ្នាំកន្លងមក ..... 55

៦.២ ភាគរយគ្រួសារមានអំពើហឹង្សាក្នុងគ្រួសារដែលបានកត់ត្រា តាមសង្កាត់ ក្នុងឆ្នាំ២០០៨ ..... 55

៦.៣ អំពើចាប់រំលោភ និងជួញដូរមនុស្សបានកត់ត្រា រយះពេល៣ឆ្នាំកន្លងមក ..... 55

៦.៤ ការចូលរួមរបស់ស្ត្រី ក្នុងរយះពេល៣ឆ្នាំកន្លងមក ..... 56

៦.៥ ភាគរយស្ត្រីចូលរួមក្នុងការងារសង្គមស៊ីវិលនិងស្ត្រីអាយុ១៨-៦០ឆ្នាំគ្មានការងារ ច្បាស់លាស់ តាមសង្កាត់ ក្នុងឆ្នាំ២០០៨ ..... 56

៦.៦ ស្ត្រីជាមេគ្រួសារ ..... 57

៦.៧ ភាគរយគ្រួសារដែលស្ត្រីជាមេគ្រួសារនិងមានកូនតូចអាយុតិចជាង៥ឆ្នាំ តាមសង្កាត់ ក្នុងឆ្នាំ២០០៨ ..... 57

៧ ស្ថិតិជនជាតិដើមភាគតិចនៅក្នុងក្រុង ..... 58

៧.១ ស្ថិតិជនជាតិដើមភាគតិចនៅក្នុងក្រុង ..... 58

៧.២ ជនជាតិភាគតិចផ្សេងៗក្នុងក្រុង ..... 58

ផ្នែក គ : ផែនការ និងគម្រោង ..... 59

៨ សំណើគម្រោងជាអាទិភាពនិងផែនការនានា ..... 61

៨.១ សំណើគម្រោងជាអាទិភាពរបស់ក្រុមប្រឹក្សាសង្កាត់ សម្រាប់ឆ្នាំ២០០៩ក្នុងក្រុងតាមវិស័យ ..... 61

៨.២ កិច្ចព្រមព្រៀងបណ្តោះអាសន្នតាមសង្កាត់ សម្រាប់ឆ្នាំ២០០៩ ..... 71

៨.៣ លទ្ធផលគម្រោង និងតម្លៃប៉ាន់ស្មាននិងជាក់ស្តែង នៃគម្រោងមូលនិធិសង្កាត់ ២០០៥-២០០៨ តាមបណ្តាសង្កាត់ ..... 90

*៨.៤ ការចំណាយនៃមូលនិធិសង្កាត់សរុប តាមបណ្តាសង្កាត់ និងវិស័យក្នុងចន្លោះ ឆ្នាំ២០០៥-២០០៨*.........93
*៨.៥ គម្រោងមូលនិធិសង្កាត់ឆ្នាំ២០០៩ដាក់ស្តែងតាមសង្កាត់*.........93
**៩ គម្រោងថ្នាក់ក្រុង ឆ្នាំ២០០៦-២០០៩**.........95
*៩.១ គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្តួចផ្តើមនៅក្រុង ឆ្នាំ២០០៦-២០០៩*.........96
*៩.២ គម្រោងសេវាកម្មផ្តួចផ្តើមនៅក្រុង ឆ្នាំ២០០៦-២០០៩*.........96
*៩.៣ គម្រោងអន្តរសង្កាត់ក្នុងឆ្នាំ២០០៨និងឆ្នាំ២០០៩*.........96
*៩.៤ គម្រោងផ្សេងៗ ឆ្នាំ២០០៨ និងឆ្នាំ២០០៩*.........97
**ផ្នែក ឃ : សេវាកម្មនិងអង្គភាព/ស្ថាប័ននានា**.........99
**១០ ហេដ្ឋារចនាសម្ព័ន្ធ**.........101
*១០.១ ប្រវែង និងការចំណាយលើ ផ្លូវ ក្នុងឆ្នាំ២០០៨ តាមបណ្តាស្រុក-ក្រុង*.........101
*១០.២ ការចំណាយលើប្រព័ន្ធស្រោចស្រពតាមខ្នាត ក្នុងឆ្នាំ២០០៨ តាមបណ្តាស្រុក-ក្រុង*.........102
*១០.៣ ការផ្គត់ផ្គង់ថាមពល ក្នុងឆ្នាំ២០០៨ តាមស្រុក-ក្រុង*.........103
**១១ សម្ភារៈបរិក្ខារសុខាភិបាល**.........104
*១១.១ សម្ភារៈបរិក្ខារសុខាភិបាលក្នុងខេត្ត តាមបណ្តាស្រុកប្រតិបត្តិ*.........104
*១១.២ សម្ភារៈបរិក្ខារ និងបុគ្គលិកសុខាភិបាល នៅថ្នាក់ស្រុកប្រតិបត្តិ*.........105
*១១.៣ ការសម្រាលកូនក្នុងឆ្នាំ២០០៧ តាមបណ្តាស្រុកប្រតិបត្តិ*.........109
**១២ ការអប់រំ**.........110
*១២.១ សាលារៀន ថ្នាក់ សិស្ស និងបុគ្គលិក តាមក្រុង*.........110
*១២.២ ចរិតលក្ខណៈ និងនាយក សាលារៀន សម្រាប់ឆ្នាំ២០០៧-២០០៨ តាមសង្កាត់*.........111
*១២.៣ ការចុះឈ្មោះចូលរៀនតាមកម្រិតអប់រំ ២០០៦-២០០៧ តាមសង្កាត់*.........111
*១២.៤ ការចុះឈ្មោះចូលរៀនតាមកម្រិតអប់រំ ២០០៧-២០០៨ តាមសង្កាត់*.........112
*១២.៥ ទិន្នភាពនៃការចុះឈ្មោះចូលរៀន ២០០៧-២០០៨ តាមសង្កាត់*.........113
*១២.៦ ស្ថានភាពអគារសាលារៀន តាមសង្កាត់*.........113
*១២.៧ ស្ថានភាពបន្ទប់រៀន និងអត្ថិភាពទីចាត់ការ និងបណ្ណាល័យដោយឡែក តាមសង្កាត់*.........114
*១២.៨ ការចូលរួមរបស់សហគមន៍ និងហិរញ្ញប្បទាន សម្រាប់ឆ្នាំ២០០៧-២០០៨ តាមសង្កាត់*.........115
*១២.៩ អត្រាលំហូរសិស្ស និងអត្រាបញ្ចប់ការសិក្សា តាមកម្រិត ឆ្នាំ២០០៦-២០០៧ តាមសង្កាត់*.........116
**១៣ បុគ្គលិក និងធនធាននានានៅក្រុង**.........117
*១៣.១ ក្រុមប្រឹក្សាក្រុង បានជាប់ឆ្នោតឆ្នាំ២០០៩*.........117
*១៣.២ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង*.........117

*១៣.៣ គណៈអភិបាល*....118

*១៣.៤ ការិយាល័យក្រោមសាលាក្រុង*....118

*១៣.៥ ការិយាល័យជំនាញក្រុង*....118

*១៣.៦ ទ្រព្យសម្បត្តិ និងសម្ភារៈរដ្ឋបាលក្រុង*....119

*១៣.៧ ចំណូលចុះបញ្ជីនៅរដ្ឋបាលក្រុង ឆ្នាំ២០០៨*....120

*១៣.៨ សេវាកម្មនៅក្រុង*....121

*១៣.៩ អង្គការសង្គមស៊ីវិលសកម្មនៅក្រុង*....121

*១៣.១០ ផ្នែកឯកជនក្នុងក្រុង*....125

**ផ្នែក ខ : ទិន្នន័យភាពក្រីក្រ**....129

**១៤ ទិន្នន័យអំពីភាពក្រីក្រ**....131

*១៤.១ អត្រាភាពក្រីក្រប៉ាន់ស្មានឆ្នាំ២០០៩ តាមសង្កាត់*....131

*១៤.២ ទិន្នន័យភាពក្រីក្របានមកពីទិន្នន័យអង្កេត*....131

# ពាក្យកាត់

| | | |
|---|---|---|
| AGR | Agriculture | កសិកម្ម |
| BR | Birth Registration | ការចុះបញ្ជីកំណើត |
| C. Pilot | Piloted Commune | ឃុំសាកល្បង |
| C/S | Commune / Sangkat | ឃុំ សង្កាត់ |
| CBO | Community-Based Organization | អង្គការសហគមន៍មូលដ្ឋាន |
| CDB | Commune Database | ទិន្នន័យមូលដ្ឋានឃុំ |
| CDPD | Commune Development and Planning Database | ទិន្នន័យមូលដ្ឋាននៃការកសាងផែនការនិងអភិវឌ្ឍឃុំ |
| CIP | Commune Investment plan | ផែនការវិនិយោគឃុំ |
| CLTS | Community Led-Total Sanitation | សហគមន៍ដឹកនាំអនុវត្តន៍អនាម័យទាំងស្រុង |
| Com Cov | Commune Covered | ឃុំគ្របដណ្តប់ |
| CPA | Complementary Package of Activities | សំណុំសកម្មភាពបង្គ្រប់ |
| CPS | Community Preschool | សាលាមត្តេយ្យសហគមន៍ |
| DANIDA | Danish International Development Agency | ទីភ្នាក់ងារដាណឺម៉ាក់ដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| DDLG | Democratic Development and Local Governance Project (EC-UNDP) | គម្រោងអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនិង អភិបាលកិច្ចមូលដ្ឋាន |
| DFID | Department For International Development (UK) | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស |
| DIP | District Initaitive Project | គម្រោងសាកល្បងពង្រឹងសមត្ថភាពថ្នាក់ស្រុក |
| DIS | District Information System | ប្រព័ន្ធព័ត៌មានស្រុក |
| District PDRD | District Office of Rural Development | ការិយាល័យអភិវឌ្ឍជនបទស្រុក |
| DIW | District Integraiton Workshop | សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក |
| DoLA | Department of Local Administration | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| Dr | Doctor | វេជ្ជបណ្ឌិត |
| DWRM | District Office of Water Resource and Meteorology | ការិយាល័យធនធានទឹក និងឧតុនិយមស្រុក |
| ECD | Early Childhood education (part of PE) | ការអប់រំក្មេងដំបូង (ផ្នែកនៃការអប់រំបឋមសិក្សា) |
| EMIS | Education Management Information System | ការគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ |
| Event IC | Celebration of International Days | ពិធីប្រារព្ធទិវាបុណ្យអន្តរជាតិ |

| | | |
|---|---|---|
| FDH | Former District Hospital | អតីតមន្ទីរពេទ្យស្រុក |
| GTZ | German Society for Technical Cooperation (Gesellschaft für Technische Zusammenarbeit GmbH) | ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ |
| Ha | Hectare | ហិចតា |
| HC | Health Center | មណ្ឌលសុខភាព |
| HC (NB) | Health Center no building | មណ្ឌលសុខភាពដែលគ្មានអគារ |
| HH | Headed Household | មេគ្រួសារ |
| HIS | Intervention for Health | អន្តរាគមន៍ផ្នែកសុខាភិបាល |
| HP | Health Post | ប៉ុស្តិ៍សុខភាព |
| ICC | Inter Commune Council | អន្តរឃុំ |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម |
| IND | Industry | ឧស្សាហកម្ម |
| Inter-commune | Inter-Commune Project Management Committee or Inter-commune project | គណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំសង្កាត់ ឬគម្រោងអន្តរឃុំសង្កាត់ |
| IO | International Organization | អង្គការអន្តរជាតិ |
| LASED | Land Allocation for Socio-Economic Development | ការបែងចែកដីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម |
| M&E | Monitoring and Evaluation | ត្រួតពិនិត្យ និងវាយតំលៃ |
| MA | Medical Assistant | ជំនួយការពេទ្យ |
| MoEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MPA | Minimum Package of Activities | កញ្ចប់សកម្មភាពអប្បបរមា |
| MW1 | Primary Midwives | ឆ្មបបឋម |
| MW2 | Secondary Midwives | ឆ្មបមធ្យម |
| NCD | National Contracts Database | ទិន្នន័យកិច្ចសន្យាថ្នាក់ជាតិ |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NRML | Natural Resources Management and Livelihood | ការគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ |
| NU1 | Primary Nurse | គិលានុបដ្ឋាយិកាបឋម |

| | | |
|---|---|---|
| NU2 | Secondary Nurse | គិលានុបដ្ឋាយិកាមធ្យម |
| OD | Operational District | ស្រុកប្រតិបត្តិ |
| Ope. Costs | Operational Costs | ចំណាយប្រតិបត្តិ |
| Others | Other Staffs | បុគ្គលិកផ្សេងទៀត |
| PBW | Public work | សាធារណៈការ |
| PDoEYS | Provincial Department of Education, Youth and Sport | មន្ទីរអប់រំយុវជននិងកីឡាខេត្ត |
| PDRD | Provincial Department of Rural Development | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| PDWRM | Provincial Department of Water Resource and Meteorology | មន្ទីរធនធានទឹក និងឧតុនិយមខេត្ត |
| PE | Parenting Education | ការអប់រំមាតាបិតា |
| PHAST | Participatory Hygiene and Sanitation Transformation | ការផ្លាស់ប្តូរទម្លាប់នៃសុខភាពអនាម័យ ដោយមានការចូលរួម |
| PHD | Provincial Health Department | មន្ទីរសុខាភិបាលខេត្ត |
| PID | Project Information Database | ទិន្នន័យព័ត៌មានគម្រោង |
| Pop 04-05 | Population Covered 2004 or 2005 | ស្ថិតិប្រជាជនឆ្នាំ ២០០៤-២០០៥ |
| PMC | Project Management Committee | គណៈកម្មការគ្រប់គ្រងគម្រោង |
| PSDD | Project to Support Democratic Development through Decentralization and Deconcentration | គម្រោងគាំទ្រការអភិវឌ្ឍប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ |
| RH | Referral Hospital | មន្ទីរពេទ្យបង្អែក |
| SIDA | Swedish International Development Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SPPA | Senior Provincial Program Advisor | ប្រធានទីប្រឹក្សាកម្មវិធីថ្នាក់ខេត្ត |
| TBA | Traditional Birth Attendant | ឆ្មបបុរាណ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNICEF | United Nations Children's Fund | មូលនិធិកុមារសហប្រជាជាតិ |
| Vil Cov | Village converage | ភូមិគ្របដណ្តប់ |
| VIL-HC | Village distance to health center | ចម្ងាយពីភូមិទៅមណ្ឌលសុខភាព |

# សទ្ទានុក្រម

| | | |
|---|---|---|
| C/S Fund | មូលនិធិឃុំសង្កាត់ | មូលនិធិឃុំសង្កាត់ ត្រូវបានបង្កើតឡើងនិងគ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ចំពោះការចំណាយផ្នែករដ្ឋបាល និង គម្រោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់។ ទំហំមូលនិធិ ត្រូវកំណត់ឡើង ជាភាគរយនៃថវិកាជាតិ (ឧ. ក្នុងឆ្នាំ២០០៩ មូលនិធិ ឃុំសង្កាត់ មានចំនួន ២.៨%នៃថវិកាជាតិឆ្នាំ២០០៨) ហើយដែលរំពឹងថា នឹងមានការកើនឡើង ជារៀងរាល់ឆ្នាំ។ ចំនួនថវិកានៃមូលនិធិឆ្នាំ២០០៩សមមូលនឹង27.643.902$ (ក្នុងនោះសម្រាប់គម្រោងអភិវឌ្ឍន៍ មានចំនួន19.272.170$ រីឯសម្រាប់ផ្នែករដ្ឋបាលមានចំនួន8.371.731$)។ ក្នុងក្របខ័ណ្ឌគម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) ធនាគារពិភពលោក នឹងទូទាត់សងទៅក្នុងមូលនិធិវិញ ចំពោះការចំណាយលើគម្រោងអភិវឌ្ឍន៍ណា ដែលត្រូវតាមលក្ខណៈវិនិច្ឆ័យរបស់ធនាគារពិភពលោក។ |
| CDB | ទិន្នន័យមូលដ្ឋាន ឃុំសង្កាត់ | ទិន្នន័យមូលដ្ឋានឃុំសង្កាត់ គឺជាទិន្នន័យមូលដ្ឋាន ដែលគ្របដណ្តប់ទូទាំងប្រទេស ហើយធ្វើការប្រមូលទិន្នន័យ តាមរយៈការបំពេញតួលេខលំអិតក្នុងសៀវភៅស្ថិតិភូមិនិងឃុំ នៅថ្នាក់ភូមិនិងឃុំ ដើម្បីផ្ញើមកមន្ទីរផែនការ និងសរុបបញ្ចូលគ្នាដោយក្រសួងផែនការ ទៅជាទិន្នន័យមូលដ្ឋានជាតិមួយ។ ទិន្នន័យប្រមូលចុងក្រោយបំផុត ដែលបានប្រើប្រាស់ក្នុងសៀវភៅនេះ គឺជាទិន្នន័យដែលបានប្រមូលចុងឆ្នាំ២០០៨។ ដោយឡែកឯកសារស្ថានភាព ឃុំសង្កាត់ ក្រុងស្រុកខណ្ឌ ខេត្តនិងរាជធានី ដែលបានផលិតចេញពីទិន្នន័យមូលដ្ឋាននេះដែរ អាចមានរក្សាទុកនៅមន្ទីរផែនការខេត្ត។ |
| CDPD | ទិន្នន័យមូលដ្ឋាន កិច្ចអភិវឌ្ឍន៍ និង ការរៀបចំផែនការ ឃុំសង្កាត់ | ទិន្នន័យមូលដ្ឋានកិច្ចអភិវឌ្ឍន៍និងការរៀបចំផែនការឃុំសង្កាត់ គឺជាទិន្នន័យដែលគ្រប់គ្រងដោយក្រសួងផែនការ សម្រាប់កត់ត្រាសកម្មភាពជាអាទិភាព និងគម្រោងផែនការនានា ដែលកំណត់ដោយក្រុមប្រឹក្សាឃុំសង្កាត់ ព្រមទាំងកិច្ចព្រមព្រៀងបណ្តោះអាសន្ន រវាងក្រុមប្រឹក្សាឃុំសង្កាត់ ជាមួយនិងអ្នកគាំទ្រនានា នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក។ ទិន្នន័យមូលដ្ឋាន នេះក៏បានកត់ត្រាលម្អិតនូវគម្រោងទាំងឡាយដែលបានអនុវត្តនៅថ្នាក់ ឃុំសង្កាត់ ក្រុងស្រុកខណ្ឌ ខេត្តនិងរាជធានី។ |
| CIP | កម្មវិធីវិនិយោគ ឃុំសង្កាត់ | កម្មវិធីវិនិយោគ ឃុំ សង្កាត់ គឺជាផែនការ៣ឆ្នាំរំកិល ដែលរៀបចំឡើង និងអនុម័តដោយក្រុមប្រឹក្សាឃុំសង្កាត់។ ឯកសារនេះ មានសកម្មភាពជាអាទិភាព និងគម្រោងដែលកំណត់ស្នើឡើង សម្រាប់ឆ្នាំខាងមុខបន្តបន្ទាប់។ |
| Commune and Sangkat | ឃុំ និងសង្កាត់ | ឃុំ (នៅតំបន់ជនបទ) និងសង្កាត់ (នៅតំបន់ប្រជុំជន) ជាថ្នាក់រដ្ឋបាលទាបជាងគេ និងមានទំហំតូចជាងគេ ក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ។ ក្រុមប្រឹក្សាថ្នាក់រដ្ឋបាលនេះ ត្រូវបានជ្រើសតាំងឡើងតាមរយៈ ការបោះឆ្នោតសកល៥ឆ្នាំ |

| | | |
|---|---|---|
| | | ម្តង ។ បច្ចុប្បន្ន ឃុំសរុបមានចំនួន១.៤១៧ឃុំ រីឯសង្កាត់ មានចំនួន ៣០៤សង្កាត់ ដែលមានភូមិសរុប ១៤.១១៩ភូមិ គ្រប់គ្រងដោយប្រធានភូមិ ដែលបាន តែងតាំងឡើងនៅក្នុងប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ។ |
| DIP | គម្រោងសាកល្បង ថ្នាក់ស្រុក | គម្រោងសាកល្បងថ្នាក់ស្រុក គឺជាគម្រោងគាំទ្ររួមគ្នាដោយមូលនិធិ MDLF និងគម្រោងPSDD ។ នៅឆ្នាំ២០០៩នេះ គម្រោងបានអនុវត្តនៅក្នុងស្រុក ចំនួន១០៦ស្រុក ដែលត្រូវជា៦០%នៃស្រុកទូទាំងប្រទេស ដោយប្រើប្រាស់ ថវិកាចំនួន៣,២លានដុល្លារ ។ គម្រោងនេះ បានផ្តោតលើការពង្រឹងសមត្ថភាព ផ្នែកកសាងផែនការ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ លទ្ធកម្មសាធារណៈ ដោយ មានការប្រកួតប្រជែង ការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាកម្ម ។ |
| DIS | ប្រព័ន្ធព័ត៌មាន ស្រុក | ប្រព័ន្ធព័ត៌មានស្រុក គឺជាប្រព័ន្ធព័ត៌មានថ្នាក់ជាតិ ដែលគ្រប់គ្រងដោយ គ.ជ.អ.ប សម្រាប់កត់ត្រា ធនធាននានា ចំនួនបុគ្គលិក ចំណូលថវិកា ហេដ្ឋារចនាសម្ព័ន្ធ និង សម្ភារៈបរិក្ខារ ដែលមានទាំងអស់នៅក្នុងក្រុងស្រុកខណ្ឌ ទាំង១៩៣ ទូទាំង ប្រទេស ។ ព័ត៌មាននេះ បានធ្វើបច្ចុប្បន្នភាពចុងក្រោយ នៅ អំឡុងខែកក្កដា ឆ្នាំ២០០៩ ។ |
| District, Municipal and Khan | ស្រុក ក្រុង និង ខណ្ឌ | ក្រុង ស្រុក និងខណ្ឌ គឺជាថ្នាក់រដ្ឋបាលលំដាប់ទី៣នៃរដ្ឋាភិបាលកម្ពុជា ។ ស្រុក នៃតំបន់ជនបទ ទាំង១៥៩ស្រុក ក្រុងនៃទីប្រជុំជនទាំង២៦ នៃខេត្ត ទាំង២៣ និងខណ្ឌទាំង៨ របស់រាជធានីភ្នំពេញ ត្រូវដឹកនាំដោយ ក្រុមប្រឹក្សា ដែលបាន ជ្រើសរើសឡើងតាមរយៈការបោះឆ្នោតអសកល សម្រាប់អាណត្តិប្រាំឆ្នាំដំបូង របស់ខ្លួន នាខែឧសភា ឆ្នាំ២០០៩ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ជា អ្នកបោះឆ្នោត តាមបែបអសកលនេះ ។ |
| DIW | សិក្ខាសាលាសមាហ រណកម្មផែនការ ថ្នាក់ស្រុក | សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ត្រូវបានរៀបចំឡើងជារៀង រាល់ឆ្នាំ ក្នុងអំឡុងពីខែកក្កដា-តុលា ដើម្បីផ្តល់ឱកាសឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ស្វែងរកអ្នកជួយគាំទ្រគម្រោងអាទិភាពរបស់ខ្លួន ក្នុងចំណោមអង្គភាព មន្ទីរជំនាញរបស់រដ្ឋាភិបាល និងភ្នាក់ងារ/អង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានបំណងចង់ជួយគាំទ្រឃុំសង្កាត់ ។ |
| ICC | គម្រោងសហ ប្រតិបត្តិការ អន្តរឃុំ | គម្រោងសហប្រតិបត្តិការអន្តរឃុំ បានអនុវត្តនៅក្នុងខេត្តចំនួន១០ គាំទ្រដោយ គម្រោងអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនិងអភិបាលកិច្ចមូលដ្ឋាន (DDLG) ។ គម្រោងរយៈពេល៥ឆ្នាំនេះ (២០០៦-២០១០) អនុវត្តដោយក្រសួងមហាផ្ទៃ ផ្តល់ហិរញ្ញប្បទានដោយសហគមន៍អឺរ៉ុបនិងUNDP ។ គម្រោងនេះ បានផ្តោត លើការជំរុញឱ្យកាន់តែប្រសើរឡើងនូវ កិច្ចពិភាក្សាក្នុងភាពជាដៃគូរ និង គណនេយ្យភាព បង្កើតឱ្យមានឡើងនូវបណ្តាញក្រុមប្រឹក្សាឃុំសង្កាត់ នៅ ថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងជួយរួមចំណែក ក្នុងការអភិវឌ្ឍន៍តំបន់ ជនបទ សំដៅកាត់បន្ថយភាពក្រីក្រ ។ ការងារមួយផ្នែក នៃគម្រោងសហប្រតិបត្តិការ អន្តរឃុំ គឺគាំទ្រការវិនិយោគ និងផ្តល់សេវាកម្ម តាមរយៈកិច្ចពិភាក្សាអន្តរ |

| | | |
|---|---|---|
| | | ឃុំសង្កាត់ និងការកសាងផែនការ ។ |
| MEDiCAM | មេឌីកាំ | មេឌីកាំ គឺជាការប្រមូលផ្តុំសមាជិកអង្គការ មិនមែនរកប្រាក់ចំណេញ និងមិនបំរើបក្ស នយោបាយ ដែលកំពុងធ្វើសកម្មភាពផ្នែកសុខភាពនៅកម្ពុជា ។ មេឌីកាំ បង្កើតឡើងជាសំខាន់ដើម្បីជាបណ្តាញសម្រាប់អង្គការ ដែលពាក់ព័ន្ធវិស័យសុខភាពនៃប្រទេសកម្ពុជា ។ |
| NCDD | គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាគណៈកម្មាធិការអន្តរក្រសួង ទទួលបន្ទុកអនុវត្តច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" អនុម័តឆ្នាំ ២០០៨ ដែលផ្តល់មូលដ្ឋានគតិយុត្តិ សម្រាប់ការអនុវត្តវិមជ្ឈការ ។ គ.ជ.អ.ប គឺជាខ្សែរយៈដែលដៃគូរអភិវឌ្ឍន៍មួយចំនួន ផ្តល់លំហូរហិរញ្ញប្បទានសមស្រប ដើម្បីអនុវត្តគម្រោងនិងកម្មវិធីនានា នៅថ្នាក់រដ្ឋបាលទាំងឡាយ ។ ដូចជាទំហំហិរញ្ញប្បទានដែលបានផ្តល់ក្នុងឆ្នាំ២០០៨ គឺស្មើនឹង៩១លានដុល្លារ ។ ព័ត៌មានលំអិត ដូចជា របាយការណ៍ សៀវភៅណែនាំ លិខិតបទដ្ឋាន ឯកសារគម្រោងលំអិត... ។ល ។អាចផ្តល់ជូនតាមគេហទំព័រ : www.ncdd.gov.kh ។ |
| OD | ស្រុកប្រតិបត្តិ | ស្រុកប្រតិបត្តិ គឺជាស្រុកដែលកំណត់និងប្រើប្រាស់ដោយក្រសួងសុខាភិបាល ។ ចំនួនស្រុកប្រតិបត្តិនេះ មិនស្របគ្នាជាមួយចំនួន១៩៣ ក្រុង ស្រុក ខណ្ឌ ដែលកំណត់និងប្រើប្រាស់ ក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈឡើយ ។ ជាទូទៅទំហំស្រុកប្រតិបត្តិ គ្របដណ្តប់លើវិសាលភាពធំជាង ស្រុកក្នុងប្រព័ន្ធរដ្ឋបាល ហើយមានចំនួនតែ ៧៧ ស្រុកប្រតិបត្តិប៉ុណ្ណោះ បើធៀបជាមួយផ្នែករដ្ឋបាល គឺមានរហូតដល់ទៅ ១៩៣ ក្រុង ស្រុក ខណ្ឌ ។ ម្យ៉ាងទៀត ព្រំប្រទល់ស្រុកប្រតិបត្តិ ក៏មិនស៊ីសង្វាក់គ្នាជាមួយព្រំប្រទល់ស្រុកនៃប្រព័ន្ធរដ្ឋបាលដែរ ។ |
| PID | ទិន្នន័យព័ត៌មានគម្រោង | ទិន្នន័យព័ត៌មាន គម្រោង (PID) គឺជាទិន្នន័យមូលដ្ឋាន ដែលគ្រប់គ្រងដោយ គ.ជ.អ.ប នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត-រាជធានី ដើម្បីតាមដានគ្រប់ទិដ្ឋភាពនៃគម្រោងរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលប្រើប្រាស់មូលនិធិឃុំសង្កាត់ ។ |
| PIF | ថវិកាវិនិយោគខេត្ត | ថវិកាវិនិយោគខេត្ត គឺជាថវិកាវិភាជន៍ចំពោះគ្រប់ខេត្តនិងរាជធានី តាមរូបមន្តកំណត់មួយផ្អែកលើចំនួនប្រជាជន ។ មួយផ្នែកនៃថវិកាវិនិយោគនេះ គឺបានកំណត់រួចជាស្រេចសម្រាប់គាំទ្រដល់សកម្មភាពកសាងផែនការ ដែលអនុវត្តដោយមន្ទីរផែនការ និងសកម្មភាពបញ្ជ្រាបយេនឌ័រនៃមន្ទីរកិច្ចការនារី ខេត្តនិងរាជធានី ។ ចំណែកថវិកាវិនិយោគ ដែលនៅសល់ "មិនទាន់កំណត់" នឹងត្រូវធ្វើការវិភាជន៍ដោយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (គ.ជ.អ.ខ) ចំពោះមន្ទីរវិស័យ ទៅតាមលក្ខណៈវិនិច្ឆ័យដែលបានបង្កើត ហើយដែលឆ្លើយតបទៅនឹងសំណើជាអាទិភាពនានា ដែលបានស្នើនិងចាត់អាទិភាពដោយ ក្រុមប្រឹក្សាឃុំសង្កាត់ ដូចដែលបានបូកសរុបបញ្ចូលទៅក្នុងតារាងម៉ាទ្រិកនៃសកម្មភាពអាទិភាពថ្នាក់ស្រុក ស្របទៅតាមផែនការថ្នាក់ជាតិនិងលក្ខណៈ |

| | | |
|---|---|---|
| | | វិនិច្ឆ័យ ក្នុងការកាត់បន្ថយភាពក្រីក្រ ជាការបន្ថែមទៅក្នុងផែនការសកម្មភាពផ្សេងទៀត និងយោងតាមការអនុវត្តរបស់មន្ទីរវិស័យក្នុងឆ្នាំកន្លងមក។ ផ្អែកតាមលក្ខខណ្ឌនៃថវិកាវិភាជន៍នេះ មន្ទីរវិស័យ ត្រូវរៀបចំចាត់ចែងគ្រោងកម្មវិធីសកម្មភាពរបស់ខ្លួន តាមរយៈ ដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក។ ចុងបញ្ចប់ ចំណាយសម្រាប់សកម្មភាពដែលបានព្រមព្រៀងបូកជាមួយ ចំណាយរដ្ឋបាល ដែលមានចំនួនមិនលើសពី២៥%នៃចំណាយសរុប នឹងត្រូវយកទៅដាក់បញ្ចូលក្នុងអនុកិច្ចសន្យា ដែលត្រូវចុះហត្ថលេខារវាង គ.ជ.អ.ខ ជាមួយនិងមន្ទីរវិស័យនេះ ដោយយោលទៅតាមកិច្ចសន្យារួមដែលចុះហត្ថលេខារវាង គ.ជ.អ.ប និង គ.ជ.អ.ខ របស់ខេត្តនិមួយៗ។ ថវិកាវិនិយោគខេត្ត មានសរុបប្រហែល ២ លាន ដុល្លា ក្នុង១ឆ្នាំ ។ |
| Province | ខេត្ត | ខេត្តទាំង២៣ និងរាជធានីភ្នំពេញ គឺជាថ្នាក់រដ្ឋបាល លំដាប់ទី២ នៃរាជរដ្ឋាភិបាលកម្ពុជា។ ថ្នាក់រដ្ឋបាលនេះ មានការប្រែប្រួលជាខ្លាំង អំពីទំហំផ្ទៃដី និងចំនួនប្រជាជន ពីតូចបំផុត ដូចជា កែប (មានប្រជាជនប្រហែល៣៦ពាន់នាក់) និងប៉ៃលិន (ប្រ.ជ ប្រហែល៧០ពាន់នាក់) និងធំទូលាយប៉ុន្តែមានប្រជាជនតិចដូចជា មណ្ឌលគីរី (ប្រ.ជ ៦០ពាន់នាក់) និងរតនៈគីរី (ប្រ.ជ ១៥៣ពាន់នាក់) រហូតដល់ធំនិងមានប្រជាជនច្រើន ដូចជា កំពង់ចាម (មានប្រ.ជ ជាង ១,៧លាន នាក់) និងកណ្ដាល (ប្រ.ជ ប្រហែល ១,៤លាននាក់)។ |
| PSDD | ភី.អេស.ឌី.ឌី | គម្រោងគាំទ្រការអភិវឌ្ឍប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ (PSDD) គាំទ្រថវិកាដោយ DFID (UK), SIDA (Sweden) និងUNDP បានអនុវត្តចាប់ពីឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០១០ (ពង្រីកបន្ដថែម ១ឆ្នាំ)។ ថវិកាគម្រោងប្រចាំឆ្នាំ ប្រែប្រួលចាប់ពី ១១លានដុល្លារទៅ១៨លានដុល្លារ។ គម្រោងនេះ ផ្ដល់ការគាំទ្របច្ចេកទេសស្នូលដល់គ.ជ.អ.ប និងចំពោះថ្នាក់ខេត្តរាជធានី ផ្ដល់ថវិកាគាំទ្រចំពោះមូលនិធិឃុំសង្កាត់ គម្រោងសាកល្បងថ្នាក់ស្រុក ថវិកាវិនិយោគខេត្ត និងការកសាងសមត្ថភាពនានា តាមរយៈការបណ្ដុះបណ្ដាល ការសិក្សាស្រាវជ្រាវ និងសេវាទីប្រឹក្សា។ |
| RILGP | អរ.អាយ.អិល.ជី.ភី | គម្រោងវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន (RILGP) គឺជាគម្រោងផ្ដល់ថវិកាដោយធនាគារពិភពលោក ដែលគាំទ្រចំពោះគម្រោងមូលនិធិឃុំសង្កាត់ សំដៅបង្កើតឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ បង្កើតបានជាគោលនយោបាយ ប្រព័ន្ធផ្សេងៗ និងសមត្ថភាពជំនាញនានា ដែលត្រូវការ។ គម្រោងនេះ បានចាប់ផ្ដើមពីឆ្នាំ២០០៣ ជាមួយនិងប្រាក់កំចី ២២លានដុល្លារ សម្រាប់ឆ្នាំ២០០៣-២០០៧ និងបានពង្រីកបន្ថែមពីឆ្នាំ២០០៧-២០១០ ក្នុងទឹកប្រាក់ជំនួយឥតសំណងចំនួន ៣៦លានដុល្លារ។ ការពិភាក្សាអំពីលទ្ធភាពរៀបចំគម្រោង RILGP ជំហានទី២ កំពុងតែប្រព្រឹត្តទៅរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក។ |

| | | |
|---|---|---|
| RPRP: | គម្រោងកាត់បន្ថយភាពក្រីក្រនៅជនបទ | គម្រោងកាត់បន្ថយភាពក្រីក្រនៅជនបទ ជាគម្រោងរយៈពេល៧ឆ្នាំអនុវត្ត ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១០ ក្រោមជំនួយហិរញ្ញប្បទានរបស់អង្គការ IFAD និងអង្គការUNDP ដែលអនុវត្តតាមរយៈក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ គាំទ្រដោយក្រសួងមហាផ្ទៃ និងសម្របសម្រួលដោយគ.ជ.អ.ប ។ គម្រោងនេះ អនុវត្តនៅក្នុងខេត្តព្រៃវែងនិងស្វាយរៀង ជាមួយគ្រួសារគោលដៅចំនួន ១២០.៦០០គ្រួសារ ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ ទិសដៅគម្រោងគឺការកាត់បន្ថយភាពក្រីក្រ ដោយមានការចូលរួមយ៉ាងសកម្មពីគ្រួសារក្រីក្រ តាមរយៈការកែលម្អជីវភាពរស់នៅ ការពង្រឹងសមត្ថភាព ប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព ការគ្រប់គ្រងធនធានធម្មជាតិ និងទិសដៅបន្ថែមថ្មីក្នុងការស្តារឡើងវិញកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនលទ្ធភាពទទួលបានបច្ចេកវិជ្ជា សេវាកម្ម ទីផ្សារ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមរបស់ក្រុមគ្រួសារគោលដៅទាំងនោះ ។ |
| RULIP | គម្រោង បង្កើនជីវភាពរស់នៅនៃតំបន់ជនបទ | គម្រោងបង្កើនជីវភាពរស់នៅនៃតំបន់ជនបទ អនុវត្តដោយអង្គភាពគាំទ្រគម្រោង(PSU)នៃក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ និងដោយមានកិច្ចសហការពីគ.ជ.អ.ប ។ គម្រោងនេះ គាំទ្រហិរញ្ញប្បទានដោយIFADនិងUNDP ហើយត្រូវអនុវត្តរហូតដល់ឆ្នាំ២០១៤ ។ ក្រុមគោលដៅគម្រោង គឺជាគ្រួសារក្រីក្រ ដែលមានដីតិចតួចឬគ្មានដីដាំដំណាំ មានចិញ្ចឹមសត្វឬទ្រព្យសម្បត្តិតិចតួច ហើយជានិច្ចកាលមានកូនឬអ្នករស់ក្នុងបន្ទុកច្រើននាក់ ។ គោលដៅចំបងរបស់គម្រោងនេះ គឺការបង្កើនដោយផ្ទាល់ឬដោយប្រយោលនូវ ប្រព័ន្ធទ្រទ្រង់ជីវភាពរស់នៅ សន្តិសុខស្បៀង និងប្រាក់ចំណូល ដល់គ្រួសារក្រីក្រនៅជនបទសរុបចំនួន ៣៣.៩០០គ្រួសារ ជនជាតិដើមភាគតិច និងគ្រួសារមានស្ត្រីជាមេគ្រួសារ នៅតាមបណ្តាភូមិគោលដៅនានា ក្នុងខេត្តក្រចេះ ព្រះវិហារ និងខេត្តរតនៈគិរី ។ |
| Seth Koma | កម្មវិធីសិទ្ធិកុមារ | កម្មវិធីសិទ្ធិកុមាររបស់UNICEF បានផ្តោតជាសំខាន់ទៅលើ សកម្មភាពជាគន្លឹះនានា ដើម្បីកុមារនិងស្ត្រី ។ នៅឆ្នាំ២០០៦-២០១០ កម្មវិធីនេះបានអនុវត្តនៅក្នុងខេត្តចំនួន៦ ។ រាជរដ្ឋាភិបាលនិងអង្គការយូនីសេហ្វ បានកំណត់គោលដៅអភិវឌ្ឍន៍ពាក់ព័ន្ធមួយចំនួន ដើម្បីដោះស្រាយបញ្ហាសំខាន់៧ នៃដំណាក់កាលវដ្តជីវិតរបស់កុមារ ដូចជា: ក) មាតាត្រូវមានសុវត្ថិភាព ក្នុងពេលមានផ្ទៃពោះ ពេលប្រសូត្របុត្រ និងមានទារកប្រកបដោយសុខភាពល្អ ។ ខ) ការចាប់ផ្តើមដ៏ប្រសើរបំផុតនូវជីវិតរបស់ទារក ។ គ) កុមារបានចូលរៀននៅពេលគ្រប់អាយុ៦ឆ្នាំ ។ ឃ) កុមារត្រូវបានការពារពីការយកធ្វើអាជីវកម្ម ពីការជួញដូរ ការរំលោភបំពាន ការធ្វើទារុណកម្ម ការរើសអើង និងផុតពីភាពប្រថុយប្រថានផ្សេងៗ ។ ង) យុវជននិងក្មេងជំទង់ មានបំណិនជីវិត អាចបញ្ចេញទស្សនៈ និងចូលរួមធ្វើការសម្រេចចិត្ត ។ |

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ដល់ការប្រើប្រាស់នូវធនធានដ៏មានកម្រិត និងចំពោះការរៀបចំកសាងផែនការ និងការគ្រប់គ្រងដោយមានការចូលរួមនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលអនុម័តនាឆ្នាំ២០០៨ បានផ្តល់នូវក្របខ័ណ្ឌគតិយុត្តិសម្រាប់ជំហានបន្តបន្ទាប់ទៅថ្ងៃអនាគត ឆ្ពោះទៅរកការលើកកម្ពស់ និងការធ្វើវិមជ្ឈការនូវការកសាងផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដាន ព្រមទាំងសំដៅបង្កើនឡើងនូវគណនេយ្យភាព និងតម្លាភាពរបស់អង្គភាពទាំងឡាយនៃរដ្ឋបាលថ្នាក់ក្រោមជាតិនានា។

រាជរដ្ឋាភិបាលបានបង្កើតឱ្យមាននូវក្រុមប្រឹក្សាដោយការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិនានា ហើយយើងនឹងបន្តផ្តល់នូវការទទួលខុសត្រូវ គួបផ្សំជាមួយនឹងធនធានមនុស្ស និងហិរញ្ញវត្ថុជាបណ្តើរៗ ដល់ក្រុមប្រឹក្សាទាំងនោះ ដើម្បីមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈនានាយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាទាំងនោះនឹងកាន់តែមានលក្ខណៈប្រជាធិបតេយ្យ មានប្រសិទ្ធភាពខ្ពស់ មានតម្លាភាព និងមានគណនេយ្យភាពកាន់តែច្រើនឡើង ក្នុងការដោះស្រាយបញ្ហាយេនឌ័រ និងភាពមិនស្មើគ្នានានា ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ជាទូទៅយើងទទួលស្គាល់ថា កិច្ចអភិវឌ្ឍមិនមែនកើតឡើងមកតែពីរដ្ឋបាលនានានោះទេ វាចាំបាច់ត្រូវមានការចូលរួមចំណែកពីប្រជាពលរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជននានា ហើយដែលប្រព័ន្ធថ្មីនេះនឹងជួយសម្របសម្រួលដល់កិច្ចដំណើរការទាំងនេះ។

ចំណុចដ៏សំខាន់បំផុតនៅក្នុងដំណើរការនេះ គឺលទ្ធភាពទទួលបាននូវព័ត៌មានគ្រប់ទិដ្ឋភាពទាំងអស់នៃកិច្ចអភិវឌ្ឍសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាក្រុង ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង មន្ទីរជំនាញដែលកំពុងប្រតិបត្តិការនៅថ្នាក់រដ្ឋបាលនេះ រួមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា ដៃគូអភិវឌ្ឍន៍ ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅទូទាំងប្រទេស ត្រូវការចាំបាច់នូវព័ត៌មានស្តីពីបញ្ហានិងសេចក្តីត្រូវការនានា ធនធាននិងកាលានុវត្តនានា សេវាកម្មនិងទីភ្នាក់ងារនានា ព្រមទាំងផែនការនិងគម្រោងនានា។ គេទាំងឡាយត្រូវការព័ត៌មានបែបនេះដើម្បីយល់បានច្បាស់លាស់អំពីស្ថានភាពបច្ចុប្បន្ន ដើម្បីធ្វើការកំណត់ពីគោលដៅទៅអនាគត ដើម្បីតាមដានលទ្ធផលរីកចម្រើន ដើម្បីយល់ដឹងអំពីអ្វីដែលអ្នកផ្សេងកំពុងតែអនុវត្ត និងដើម្បីប្រើប្រាស់ធនធានប្រកបដោយគតិបណ្ឌិត ដែលនេះគឺជាហេតុផលចម្បងដែលត្រូវឱ្យតម្លៃដល់សៀវភៅទិន្នន័យក្រុង ស្រុក ខណ្ឌនេះ។

សៀវភៅទិន្នន័យក្រុង ស្រុក ខណ្ឌ គឺជាជំហានមួយដ៏សំខាន់ឆ្ពោះទៅរកតម្លាភាពពេញលេញ និងសម្រាប់ការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយភាពត្រឹមត្រូវជាក់លាក់។ សៀវភៅនេះ

នឹងផ្តល់ជូននូវទិន្នន័យព័ត៌មានទាំងអស់តាមលទ្ធភាពដែលមាននៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ តាមទម្រង់ងាយស្រួលអាន ជាភាសាខ្មែរ និងអង់គ្លេស។ សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយចំនួន ១៦.០០០ក្បាល ការចម្លងចូលស៊ីឌី និងការដាក់ផ្សាយនៅក្នុងគេហទំព័ររបស់ គ.ជ.អ.ប (www.ncdd.gov.kh)។

នេះគឺជាលើកទី១ហើយនៅក្នុងប្រទេសកម្ពុជា (និងអាចជាលើកដំបូងនៅក្នុងអាស៊ីអាគ្នេយ៍) ដែលព័ត៌មានលំអិតបែបនេះ ត្រូវបានរៀបចំឱ្យកើតមានឡើងសម្រាប់ប្រើប្រាស់យ៉ាងទូលំទូលាយ ដែលគួរកោតសរសើរដល់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែងសម្រេចកិច្ចការដ៏លំបាកនេះ។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះថ្លែងអំណរគុណចំពោះក្រសួងផែនការ ដែលបានផ្តល់ព័ត៌មានលំអិតនៅក្នុងកម្រងព័ត៌មានទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងសូមថ្លែងអំណរគុណចំពោះក្រសួងជំនាញ និងអាជ្ញាធរខេត្តនានាដែលបានរួមចំណែកផ្តល់ទិន្នន័យជាច្រើនផងដែរ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុចំពោះការងារនេះផងដែរ។

យើងសង្ឃឹមជឿជាក់ថា ការបោះផ្សាយសៀវភៅទិន្នន័យក្រុង ស្រុក ខណ្ឌនេះ នឹងជួយរួមចំណែកពង្រឹងសមត្ថភាព ជាពិសេសចំពោះរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងកិច្ចការរៀបចំផែនការអភិវឌ្ឍន៍ដោយផ្អែកលើទន្និករណ៍ច្បាស់លាស់។ យើងក៏សង្ឃឹមផងដែរថា ព័ត៌មានទាំងនេះនឹងជួយឱ្យក្រសួងជំនាញ អាជ្ញាធរខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលនានា និងទីភ្នាក់ងារស្រាវជ្រាវទាំងឡាយ យល់កាន់តែស៊ីជម្រៅអំពីស្ថានភាពពិតប្រាកដរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទាំងឡាយ។

យើងខ្ញុំសូមអំពាវនាវចំពោះអ្នកពាក់ព័ន្ធទាំងអស់ សូមជួយប្រើប្រាស់ និងផ្សព្វផ្សាយព័ត៌មានទាំងនេះ និងសូមជួយបំពេញបន្ថែម ឬកែតម្រូវទិន្នន័យនានាដែលចាំបាច់ ដើម្បីរួមចំណែកដល់ការធ្វើបច្ចុប្បន្នភាពទិន្នន័យនៅឆ្នាំខាងមុខជាបន្តបន្ទាប់ទៀត។



**ស ខេង**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ

តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីផ្តើម

## គោលបំណង

គោលបំណងសំខាន់នៃសៀវភៅទិន្នន័យនេះ គឺការប្រមូលផ្តុំបញ្ចូលគ្នានូវព័ត៌មានគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតនិងកិច្ចអភិវឌ្ឍន៍ក្រុងស្រុកខណ្ឌ និងឃុំសង្កាត់ ដើម្បីអាចចែករំលែកចំណេះដឹងបានយ៉ាងទូលំទូលាយ។ សៀវភៅដែលបានផលិតឡើងនេះ គឺសម្រាប់ផ្តល់ជូនក្រុមប្រឹក្សាក្រុងស្រុកខណ្ឌដែលទើបបានបោះឆ្នោតជ្រើសរើស គណៈអភិបាលក្រុងស្រុកខណ្ឌ ការិយាល័យជំនាញថ្នាក់ក្រុងស្រុកខណ្ឌ អង្គភាពនានានៅថ្នាក់ខេត្ត រាជធានី និងដៃគូរអភិវឌ្ឍន៍ ព្រមទាំងអង្គការនានា ដែលកំពុងអនុវត្តសកម្មភាពនៅថ្នាក់រដ្ឋបាលនេះ ហើយនិងត្រូវការយល់ដឹងលម្អិតអំពីល័ក្ខខ័ណ្ឌនៃជីវភាពរស់នៅបច្ចុប្បន្ន អំពីធនធានធម្មជាតិនានា អំពីហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗ ព្រមទាំងកិច្ចសេវាកម្មបច្ចុប្បន្ន អំពីគម្រោងដែលបានអនុវត្តនិងគ្រោងអនុវត្ត ព្រមទាំងអំពីធនធាននានា ដែលមាននៅថ្នាក់រដ្ឋបាលនេះផងដែរ។

ដោយសារតែមានព័ត៌មានជាច្រើនរួចមកហើយ ទាំងទងទៅនឹងទិដ្ឋភាពទាំងឡាយ ដែលបានលើកឡើងខាងលើនេះ ដូច្នេះយើងមានការលំបាកក្នុងការវាយតម្លៃថាតើមានព័ត៌មានអ្វីខ្លះនិងមានចំនួនប៉ុន្មាន ដែលខ្វះខាតមិនបានបញ្ចូលទៅក្នុងរបាយការណ៍ ទៅក្នុងទិន្នន័យមូលដ្ឋាន និងទៅក្នុងកម្រងស្ថិតិ ហើយដែលមិនទាន់បានធ្វើការចែករំលែកឱ្យបានទូលំទូលាយនៅឡើយ។ ទិន្នន័យភាគច្រើនមានទំរង់ជាភាសាតែមួយ ហើយនិងមិនទាន់បានធ្វើបច្ចុប្បន្នភាពទៀតផង ហើយខ្លះទៀតក៏មានតែសម្រាប់វិស័យមួយឬតំបន់មួយប៉ុណ្ណោះ។

យើងបានដឹងថាបញ្ហាទាំងប៉ុន្មានខាងលើនេះ ភាគច្រើនបានធ្វើឱ្យមានការមិនសូវពេញចិត្ត ជាពិសេសនៅថ្នាក់ក្រុងស្រុកខណ្ឌ។ ពេលនេះ រដ្ឋបាលថ្នាក់ក្រុងស្រុកខណ្ឌ បានក្លាយទៅជាថ្នាក់ដ៏មានសារៈសំខាន់មួយ នៅក្នុងកិច្ចការរដ្ឋបាលមូលដ្ឋាន ដូច្នេះតម្រូវការបន្ទាន់ចំពោះមុខ គឺការទទួលបាននូវកម្រងទិន្នន័យដ៏សំបូរបែប សម្រាប់ប្រើប្រាស់ក្នុងការកំណត់បន្ទាត់ដ្ឋាន ការរៀបចំផែនការអភិវឌ្ឍន៍ ការចាត់អាទិភាព ការតាមដាននិងសិក្សាស្វែងយល់ពីបទពិសោធន៍នានាកន្លងមក។

## វិធីសាស្ត្រ

យើងបានព្យាយាមកំណត់ប្រភេទនិងបូកសរុបតួលេខស្ថិតិនានា ព្រមទាំងរបាយការណ៍ទាំងអស់ដែលមានរួមទាំងផែនទីនិងទិន្នន័យនៅថ្នាក់ក្រុងស្រុកខណ្ឌ ឬ ថ្នាក់ឃុំសង្កាត់ទាំងឡាយ។ ក្នុងន័យនេះ យើងបានជ្រើសយកព័ត៌មានដែលមាននៅគ្រប់ក្រុងស្រុកខណ្ឌ ឬមាននៅក្រុងស្រុកខណ្ឌភាគច្រើន ហើយដែលជាព័ត៌មានសមហេតុផលគួរទុកចិត្តបាន និងថ្មីៗបំផុត ព្រមទាំងជាព័ត៌មានដែលមានលក្ខណៈល្អិតល្អន់គ្រប់គ្រាន់ ដែលអ្នកកសាងផែនការអភិវឌ្ឍន៍ អ្នកធ្វើសេចក្តីសម្រេចចិត្ត ទីភ្នាក់ងារផ្សេងៗ និងប្រជាពលរដ្ឋភាគច្រើន មានចំណាប់អារម្មណ៍បំផុត។

ប្រភពព័ត៌មានទាំងអស់ នៅក្នុងសៀវភៅទិន្នន័យក្រុងស្រុកខណ្ឌនេះ គឺបានមកពី ៖

ក) កម្រងទិន្នន័យមូលដ្ឋានឃុំសង្កាត់ ដែលបានប្រមូលចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ (ទិន្នន័យចុងក្រោយបំផុត ប្រមូលនៅចុងឆ្នាំ ២០០៨)។

ខ) ព័ត៌មានលំអិតបានដោយផ្ទាល់ពីក្រសួងសុខាភិបាល ក្រសួងអប់រំយុវជននិងកីឡា និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (ផែនទី) ។

គ) ទិន្នន័យព័ត៌មានគម្រោងមូលនិធិឃុំ (PID) នៅគ.ជ.អ.ប (ថ្មីបំផុត) ។

ឃ) ទិន្នន័យផែនការនិងការអភិវឌ្ឍន៍ឃុំ (CDPD) (ថ្មីបំផុត) ។

ង) ប្រព័ន្ធព័ត៌មានស្រុក (DIS) (ដែលបានធ្វើបច្ចុប្បន្នភាពនៅពាក់កណ្តាលឆ្នាំ២០០៩) ។

ច) ទិន្នន័យប្រមូលដោយផ្ទាល់ពីថ្នាក់ខេត្ត និងស្រុក ស្តីពីវិស័យឯកជន ប្រព័ន្ធធារាសាស្ត្រ ផ្លូវគមនាគមន៍ អគ្គិសនីតាមរយៈអង្គភាពនានាថ្នាក់ខេត្ត ។

ឆ) ទិន្នន័យវេជ្ជសាស្ត្រនិងសុខភាព ពីអង្គការមេឌីកាំ (MediCam) ។

ជ) ទិន្នន័យពីគម្រោងកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (ID Poor) ។

ឈ) ការកំណត់អត្រាភាពក្រីក្រដោយគ.ជ.អ.ប ។

ញ) ព័ត៌មានអំពី លទ្ធផលគម្រោង ការចំណាយ និងថវិការបស់គម្រោងជាក់លាក់មួយចំនួន ដូចជា គម្រោងសិទ្ធកុមារ គម្រោងRILGP គម្រោងRPRP និងគម្រោង ICC ជាដើម ។ល ។

## ភាពមានកំរិតនៃទិន្នន័យ

យើងទទួលស្គាល់ថា ទិន្នន័យដែលប្រមូលបានមកនេះ ប្រាកដជាមិនអាចពេញលេញទាំងស្រុង និងមានភាពស៊ីសង្វាក់ឬត្រឹមត្រូវជាក់លាក់ឥតខ្ចោះនោះឡើយ ។ ហេតុនេះ យើងបានបោះបង់ចោលនូវទិន្នន័យមួយចំនួន ដែលយើងយល់ថាមិនត្រឹមត្រូវ ឬមិនពេញលេញ ហើយក៏យើងបានសម្រេចចិត្តថា នឹងមិនព្យាយាមរៀបចំឱ្យបានត្រឹមត្រូវឥតខ្ចោះជាទម្រង់វិទ្យាសាស្ត្រស្ថិតិនោះដែរ យើងគ្រាន់តែបញ្ចូលនូវពតិមានទាំងអស់ ដែលយើងយល់ថាមានសារៈប្រយោជន៍ ពាក់ព័ន្ធចំពោះស្ថានភាពជាក់ស្តែង និងមានលក្ខណៈគ្រប់ជ្រុងជ្រោយប៉ុណ្ណោះ ។ យើងយល់ស្របថាគួរដាក់បញ្ចូលទិន្នន័យដូចគ្នាពីប្រភពផ្សេងគ្នា ដើម្បីលើកទឹកចិត្តឱ្យមានការពិភាក្សា អំពីគុណភាពនៃទិន្នន័យ ដែលទទួលបានពីប្រភពផ្សេងៗទាំងនោះ ។

យើងសូមទទួចនិងលើកទឹកចិត្ត ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងឡាយ ដែលបានធ្វើការកត់សម្គាល់អំពីកំរិតល្អៀង ភាពខុសឆ្គង ឬ កត់សម្គាល់អំពីភាពមិនពេញលេញផ្សេងៗនៃទិន្នន័យទាំងអស់នេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ធ្វើការទាក់ទង និងផ្តល់ព័ត៌មានទាំងអស់នោះ មកយើងខ្ញុំ ដើម្បីកែសម្រួលដែលតាមរយៈនេះ យើងសង្ឃឹមថា នៅពេលផលិតសៀវភៅទិន្នន័យក្រុងស្រុកខណ្ឌប្រភេទនេះលើកក្រោយ យើងនឹងអាចរកបាននូវប្រភពទិន្នន័យជាច្រើន ដែលមានលក្ខណៈកាន់តែពេញលេញគ្រប់គ្រាន់ថែមទៀត ។

យើងសូមលើកទឹកចិត្តចំពោះរដ្ឋបាលថ្នាក់ក្រុងស្រុកខណ្ឌ ដែលទទួលបានទិន្នន័យទាំងនេះ ជាទម្រង់ច្បាប់អេឡិចត្រូនិច សូមកុំប្រើប្រាស់ត្រឹមតែសម្រាប់ការកសាងផែនការនិងតាមដានការវិវឌ្ឍន៍រីកចំរើនរបស់ខ្លួន តែសូមចាប់ផ្តើមធ្វើការកែតម្រូវនិងធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងអស់នេះ ព្រមទាំងផ្តល់ត្រឡប់មកគ.ជ.អ.បវិញ សម្រាប់ប្រើប្រាស់នៅពេលអនាគត ។

## ឧបទ្ទេសមាតិកា

ព័ត៌មាននៅក្នុងទំព័របន្តបន្ទាប់នៃសៀវភៅនេះ ត្រូវបានរៀបចំជា៥ផ្នែកដូចតទៅ :

**ផ្នែកក : ភូមិសាស្ត្រ :** ផ្នែកនេះមានផ្តល់ជូននូវផែនទីផ្សេងៗ ដែលមានព័ត៌មាន អំពីហេដ្ឋារចនាសម្ព័ន្ធ និងរដ្ឋបាល អំពីដីប្រើប្រាស់និងធនធានធម្មជាតិនានា ។ ផែនទីនេះ មានផលិតជាផ្ទាំងធំៗ ចែកជូនគ្រប់ក្រុងស្រុក ខណ្ឌ ផងដែរ ។

**ផ្នែក ខ : ស្ថានភាពក្រុងស្រុកខណ្ឌ :** ផ្នែកនេះ បង្ហាញអំពីទិន្នន័យជាច្រើន ក៏រិតថ្នាក់ក្រុងស្រុកខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដែលប្រមូលបាន តាំងពីឆ្នាំ២០០៦ រហូត ដល់២០០៩ និងបានបញ្ចូលនៅក្នុងកម្រងទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ប៉ុន្តែនៅពេលដក់ស្រង់មកប្រើប្រាស់ យើងបានធ្វើការកែសម្រួលទម្រង់តារាងខ្លះៗ ដើម្បីឱ្យងាយយល់ ។

**ផ្នែក គ : ផែនការ និងគម្រោង :** ផ្នែកនេះបង្ហាញ ពីគម្រោងឬសកម្មភាពអភិវឌ្ឍន៍ជាអាទិភាពនានា ដែលបានកំណត់ចាត់អាទិភាពដោយក្រុមប្រឹក្សាឃុំសង្កាត់ កិច្ចព្រមព្រៀងបណ្តោះអាសន្ន លទ្ធផលនិងថវិកាចំណាយចំពោះគម្រោងសំខាន់នៅថ្នាក់ឃុំសង្កាត់ និងក្រុងស្រុកខណ្ឌ ចាប់តាំងពីឆ្នាំ២០០៦ ដល់២០០៨ ព្រមទាំងផែនការនិងថវិកាគ្រោងសម្រាប់ឆ្នាំ២០០៩ ។

**ផ្នែក ឃ : អង្គការ និងសេវាកម្ម :** ផ្នែកនេះមានពត៌មានលំអិត អំពីហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ (ដូចជា ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ អគ្គីសនី និងប្រព័ន្ធធារាសាស្ត្រ...ជាដើម ។ល ។) ព្រមទាំងសេវាកម្មនានា នៅក្នុងវិស័យសុខាភិបាលនិងអប់រំនៅថ្នាក់ក្រុងស្រុកខណ្ឌ និងឃុំសង្កាត់ ។ ផ្នែកនេះក៏មានព័ត៌មាន អំពីសារពើភ័ណ្ឌធនធានរបស់រដ្ឋបាលថ្នាក់ក្រុងស្រុកខណ្ឌ របស់អង្គការនានាដែលកំពុងប្រតិបត្តិការ និងរបស់វិស័យឯកជនដែលមានសកម្មភាពនៅក្នុងស្រុកនោះ ។

**ផ្នែក ង : ព័ត៌មានផ្សេងៗ :** ផ្នែកនេះ មានព័ត៌មានអំពីអត្រាភាពក្រីក្រឆ្នាំ២០០៩ របស់គ្រប់ក្រុងស្រុកខណ្ឌ និង ឃុំ សង្កាត់ ព្រមទាំង ទិន្នន័យភាពក្រីក្រលំអិតដែលបានបូកសរុបនិងកែឆ្នៃដោយគម្រោងកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ នៅក្នុងតំបន់ដែលគម្រោងនោះកំពុងប្រតិបត្តិការ ។

## សម្រាប់ពេលអនាគតខាងមុខ

យើងជឿជាក់ថា នេះគឺជាការចាប់ផ្តើមនូវដំណើរការរយៈពេលវែងដ៏ល្អប្រសើរមួយ ហើយយើងក៏សង្ឃឹមដែរថាការរៀបចំសៀវភៅទិន្នន័យក្រុងស្រុកខណ្ឌលើកក្រោយ នឹងមានដាក់បញ្ចូលនូវព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយមានភាពជាក់លាក់ និងជាព័ត៌មានថ្មីៗបំផុត ។ យើងសង្ឃឹមថា រដ្ឋបាលថ្នាក់ក្រុងស្រុកខណ្ឌ មិនត្រឹមតែចាប់ផ្តើមប្រើប្រាស់សៀវភៅនេះទេ តែនឹងធ្វើការកែលម្អ និងធ្វើបច្ចុប្បន្នភាពសៀវភៅនេះទៀតផង ជាពិសេសការកែតម្រូវទៅលើច្បាប់អេឡិចត្រូនិចដែលបានផ្តល់ជូន ។

យើងសូមស្នើ អង្គភាពនានា អ្នកអនុវត្តគម្រោង អ្នកឯកទេសទាំងឡាយ សូមផ្ញើរបាយការណ៍ ស្ថិតិ ផែនទី មកយើង ដើម្បីយើងអាចយកមកដាក់បញ្ចូលទៅក្នុងសៀវភៅទិន្នន័យក្រុងស្រុកខណ្ឌ ដែលត្រូវបោះពុម្ពលើកក្រោយ ហើយក៏សូមស្នើអ្នកប្រើប្រាស់សៀវភៅនេះទាំងអស់គ្នា សូមផ្តល់ព័ត៌មានត្រឡប់មកយើងខ្ញុំវិញ អំពីកំហុសឆ្គងនានា យោបល់កែតម្រូវឱ្យស្របទៅតាមបច្ចុប្បន្នភាព និងការកត់សម្គាល់អំពីភាពមិនស្របគ្នានៃផ្នែកណាមួយនោះនៃទិន្នន័យព័ត៌មាន មកយើងតាមរយៈអ៊ីម៉ែល info@ncdd.gov.kh ។

ជាបន្ត យើងសូមអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី ពិនិត្យមើលសៀវភៅនេះត្រួសៗសិន ដោយបើកមើលចោះៗ ឬក៏ពិនិត្យមើលមាតិកាអត្ថបទ ដើម្បីកំណត់រកផ្នែកណាមួយដែលគួរជាទីចាប់អារម្មណ៍ បំផុត ។

យើងសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងបានដឹងព័ត៌មាននានា ហើយនឹងអាចមានការភ្ញាក់ផ្អើល និងជួយគាំទ្រចំពោះការរៀបចំសៀវភៅនេះមិនខានឡើយ ។ យើងក៏សង្ឃឹមដែរថា អ្វីទាំងអស់នេះនឹងនាំមកនូវចំណេះដឹង កាន់តែទូលំទូលាយ អំពី ហេតុនិងផលនៃភាពក្រីក្រ ព្រមទាំងអាចធ្វើការសម្រេចចិត្តថាតើត្រូវដោះស្រាយមូលហេតុទាំងនោះយ៉ាងដូចម្តេច ប្រកបដោយតម្លាភាពខ្ពស់ ដោយប្រើប្រាស់ធនធានដ៏ស្តួចស្តើងរបស់ខ្លួន ក្នុងគោលបំណងបំរើផលប្រយោជន៍ទាំងអស់គ្នា ។

**ម៉ាធីន ឌី ក្រាហ្វ**
ទីប្រឹក្សាកម្មវិធី
PSDD/NCDD

# ផ្នែក ក : ភូមិសាស្ត្រ

# ១. ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងរដ្ឋបាល

*ទំព័រនេះនឹងជំនួសដោយផែនទីជាក់ស្តែង មានពណ៌ ទំហំA៣*

# ២. ផែនទីធនធានធម្មជាតិ និងប្រើប្រាស់ដី

*ទំព័រនេះនឹងជំនួសដោយផែនទីធនធានធម្មជាតិនិងប្រើប្រាស់ជាក់ស្តែង មានពណ៌ ទំហំអា៣*

# ៣ ផ្ទៃដី

## ៣.១ ផ្ទៃដី (ហិចតា)

| ផ្ទៃដីសរុប (ហ.ត) | ផ្ទៃដីព្រៃ (ហ.ត) | | ផ្ទៃដីដាំដុះ (ហ.ត) | ផ្ទៃដីលំនៅដ្ឋាន (ហ.ត) | ផ្ទៃដីផ្សេងៗ (ហ.ត) |
|---|---|---|---|---|---|
| | សរុប | ព្រៃលិចទឹក | | | |
| 55,088 | 26,399 | - | 25,851 | 2,660 | 178 |

## ៣.២ ចម្ងាយរវាងទីរួមខេត្ត ក្រុង និងសង្កាត់

| ទីតាំង | ចម្ងាយ (គម) |
|---|---|
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ ទឹកថ្លា | 0 |
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ កំពង់ស្វាយ | 0 |
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ កោះពងសត្វ | 0 |
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ ម្កាក់ | 0 |
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ អូរអំបិល | 0 |
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ ភ្នៀត | 0 |
| ពីសាលាស្រុកទៅសាលាឃុំ សង្កាត់ ព្រះពន្លា | 0 |

# ផ្នែក ខ : ស្ថានភាពក្រុង[១]

[១] ទិន្នន័យទាំងអស់នៅក្នុងផ្នែកនេះ បានមកពីទិន្នន័យមូលដ្ឋានឃុំ(CDB) លើកលែងតែមានការបញ្ជាក់បន្ថែម ដែលរួមមានទិន្នន័យប្រមូលចុងឆ្នាំ២០០៨ និងឆ្នាំមុន១ ។ សូមកត់សំគាល់ថា ចំនួនភាគរយដែលបានគណនា ត្រូវបានបង្គត់ត្រឹម១ឬ២ខ្ទង់ទសភាគ ។

# ១. ព័ត៌មានទូទៅ

## ១.១ ស្ថិតិប្រជាជន

### ១.១.១ ប្រជាជនសរុប

| ចំនួនគ្រួសារ | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|
| ចំនួនគ្រួសារសរុប | 16,790 គ្រួសារ | 16,483 គ្រួសារ | 16,576 គ្រួសារ | 19,394 គ្រួសារ |
| ចំនួនគ្រួសារថយចុះ/កើនឡើង | | -2% | 1% | 17% |
| ចំនួនប្រជាជនសរុប | 90,782 នាក់ | 81,242 នាក់ | 81,960 នាក់ | 95,110 នាក់ |
| ចំនួនប្រជាជនសរុបថយចុះ/កើនឡើង | | -11% | 1% | 16% |
| ចំនួនគ្រួសារដែលស្ត្រីជាមេគ្រួសារ | 2,401 គ្រួសារ | 2,334 គ្រួសារ | 2,235 គ្រួសារ | 2,459 គ្រួសារ |

***សម្គាល់*** : ភាគរយកើន/ថយ ត្រូវបានគណនាតាមវិធីសាមញ្ញ ដោយយកតួលេខឆ្នាំនេះ ដកឆ្នាំមុន ចែកនិងឆ្នាំមុន រួចគុណនិង១០០ភាគរយ ។ សញ្ញាអវិជ្ជមានខាងមុខនៃភាគរយបង្ហាញការថយចុះស្ថិតិប្រជាជន ។

### ១.១.២ ចំនួនប្រជាជនតាមបណ្តាសង្កាត់ក្នុងឆ្នាំ ២០០៨




### ១.១.៣ ចំនួនប្រជាជនតាមក្រុមអាយុ រយៈពេល៣ឆ្នាំ កន្លងមក

| ស្ថិតិតាមក្រុមអាយុ | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| ចំនួនប្រជាជនសរុបអាយុពី ០-៥ ឆ្នាំ | 12% | 13% | 12% | 11,497 នាក់ |
| ប្រុស ០-៥ ឆ្នាំ | 48% | 49% | 50% | 5,733 នាក់ |
| ស្រី ០-៥ ឆ្នាំ | 52% | 51% | 50% | 5,764 នាក់ |
| | | | | |
| ចំនួនប្រជាជនសរុបអាយុពី ៦-១៧ ឆ្នាំ | 33% | 32% | 32% | 30,615 នាក់ |
| ប្រុស ៦-១៧ ឆ្នាំ | 49% | 49% | 51% | 15,521 នាក់ |
| ស្រី ៦-១៧ ឆ្នាំ | 51% | 51% | 49% | 15,094 នាក់ |
| | | | | |

| ស្ថិតិតាមក្រុមអាយុ | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| ចំនួនប្រជាជនសរុបអាយុពី ១៨-៦០ ឆ្នាំ | 50% | 51% | 50% | 47,982 នាក់ |
| ប្រុស ១៨-៦០ ឆ្នាំ | 48% | 48% | 48% | 22,974 នាក់ |
| ស្រី ១៨-៦០ ឆ្នាំ | 52% | 52% | 52% | 25,008 នាក់ |
| | | | | |
| ចំនួនប្រជាជនសរុបអាយុពី ៦១ ឆ្នាំឡើង | 5% | 5% | 5% | 5,016 នាក់ |
| ប្រុស ៦១ ឆ្នាំឡើង | 44% | 46% | 41% | 2,071 នាក់ |
| ស្រី ៦១ ឆ្នាំឡើង | 56% | 54% | 59% | 2,945 នាក់ |

***សម្គាល់***: ភាគរយ គណនាតាមចំនួនប្រជាជនសរុបនៃក្រុមនិមួយៗ ។

## ១.២ ស្ថានភាពមុខរបរប្រជាជន

### ១.២.១ ស្ថានភាពមុខរបរប្រជាជន រយៈពេល៣ឆ្នាំកន្លងមក

*តារាងនេះបង្ហាញពីភាគរយប្រជាជនដែលមានមុខរបរពិតប្រាកដ ឧទាហរណ៍ កសិករធ្វើស្រែ សិប្បកម្មសង្ហារឹម អ្នកជំនួញ ។ល ។*

| បរិយាយ | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| **គ្រួសារមានមុខរបរធ្វើកសិកម្មជាចំបង** | 52% | 48% | 53% | 10,219 គ្រួសារ |
| គ្រួសារមានមុខរបរធ្វើស្រែជាចំបង | 45% | 41% | 46% | 9,017 គ្រួសារ |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលវែងជាចំបង | 0% | 0% | 0% | 46 គ្រួសារ |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលខ្លីជាចំបង | 4% | 4% | 4% | 712 គ្រួសារ |
| គ្រួសារមានមុខរបរដាំបន្លែជាចំបង | 2% | 2% | 2% | 311 គ្រួសារ |
| គ្រួសារមានមុខរបរនេសាទជាចំបង | 0% | 1% | 1% | 108 គ្រួសារ |
| គ្រួសារមានមុខរបរចិញ្ចឹមសត្វជាចំបង | 1% | 0% | 0% | 17 គ្រួសារ |
| គ្រួសារមានមុខរបរពីអនុផលព្រៃឈើជាចំបង | 0% | 0% | 0% | 8 គ្រួសារ |
| | | | | |
| **គ្រួសារមានមុខរបរធ្វើសិប្បកម្មជាចំបង** | 0% | 0% | 0% | 74 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផលិតសង្ហារឹមពីឈើ ផ្តៅ ឬស្សី | 0% | 0% | 0% | 27 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផលិតពីដែក កញ្ចក់ អាលុយមីញ៉ូម | 0% | 0% | 0% | 17 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផលិតគ្រឿងបរិភោគ | 0% | 0% | 0% | 23 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផលិតពោះវៀនកង់ ម៉ូតូ | 0% | 0% | 0% | 0 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មត្បាញរវៃ ក្រមា ហូល... | 0% | 0% | 0% | 0 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផ្សេងៗ | 0% | 0% | 0% | 7 គ្រួសារ |
| | | | | |
| **គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង** | 26% | 32% | 27% | 5,225 គ្រួសារ |
| គ្រួសារប្រកបមុខរបរជំនួញ | 13% | 17% | 14% | 2,716 គ្រួសារ |
| គ្រួសារប្រកបមុខរបរជាង | 2% | 2% | 1% | 288 គ្រួសារ |

| បរិយាយ | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| គ្រួសារប្រកបមុខរបរដឹកជញ្ជូន | 6% | 3% | 4% | 793 គ្រួសារ |
| គ្រួសារប្រកបមុខរបរសេវាកម្មផ្សេងៗ | 5% | 10% | 7% | 1,428 គ្រួសារ |
| | | | | |
| គ្រួសារដែលប្រកបមុខរបរមិនច្បាស់លាស់(ចំរុះ) | 22% | 20% | 20% | 3,876 គ្រួសារ |

*សម្គាល់: ភាគរយមុខរបរគណនាផ្អែកលើមូលដ្ឋាននៃចំនួនគ្រួសារសរុប*

## ១.២.២ មុខរបរនិមួយៗក្នុងចំណោមរបរសំខាន់ទាំងបួនរបស់ប្រជាជនតាមសង្កាត់ ក្នុងឆ្នាំ២០០៨

*ក្រាភិចនេះ បង្ហាញភាគរយនៃគ្រួសារនិមួយៗដែលពាក់ព័ន្ធក្នុងមុខរបរបួនសំខាន់ៗ: កសិកម្ម សិប្បកម្ម សេវាកម្ម និងមុខរបរមិនជាក់លាក់ ។ គួរកត់សម្គាល់ថា កសិកម្មរួមបញ្ចូលទាំងសកម្មភាពព្រៃឈើ ដូចជា កាប់ឈើ និងប្រមូលជ័រឈើ .. ។ល ។*




*សម្គាល់: គណនាផ្អែកលើមូលដ្ឋាននៃចំនួនគ្រួសារសរុបក្នុងសង្កាត់*

## ១.២.៣ ភាគរយគ្រួសារដែលមានសមាជិកគ្រួសារ ធ្វើការក្នុងវិស័យសាធារណៈ វិស័យឯកជន និងមានការងារមិនពិតប្រាកដ ក្នុងរយៈពេល៣ឆ្នាំកន្លង

| បរិយាយ | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| គ្រួសារដែលមានសមាជិកធ្វើការនៅក្នុងក្របខណ្ឌរដ្ឋ | 8% | 7% | 7% | 1,354 គ្រួសារ |
| គ្រួសារដែលមានសមាជិកជាបុគ្គលិក-កម្មករក្នុងក្របខណ្ឌឯកជន | 3% | 3% | 3% | 530 គ្រួសារ |
| | | | | |
| ចំនួនមនុស្សអាយុពី១៨-៦០ឆ្នាំគ្មានការងារធ្វើពិតប្រាកដ និងទៀងទាត់ | 25% | 21% | 24% | 11,532 គ្រួសារ |

***សម្គាល់:*** *ភាគរយនៅក្នុងជួរ២ខាងលើបានគណនាផ្អែកលើមូលដ្ឋាននៃចំនួនគ្រួសារសរុប ។ រីឯនៅជួរទី៣ខាងក្រោមបង្អស់ បានគណនាភាគរយដោយផ្អែកតាម ចំនួនប្រជាជនសរុបនៃក្រុមអាយុចន្លោះពី១៨ ដល់៦០ ឆ្នាំ ។*

### ១.២.៤ ភាគរយគ្រួសារមានសមាជិកជាមន្ត្រីរាជការ-បុគ្គលិក-កម្មករ តាមបណ្ដាសង្កាត់ ក្នុងឆ្នាំ២០០៨




*សម្គាល់: ភាគរយគណនាធៀបតាមចំនួនគ្រួសារសរុប*

### ១.២.៥ ភាគរយប្រជាជនអាយុ១៨-៦០ឆ្នាំ មានការងារមិនពិតប្រាកដ តាមសង្កាត់ ឆ្នាំ២០០៨។




## ១.៣ ទ្រព្យសម្បត្តិ

### ១.៣.១ ស្ថានភាពលំនៅស្ថាន និងសម្ភារៈរយៈពេល៣ឆ្នាំ

*តារាងនេះ បង្ហាញពីភាគរយប្រជាជននៅក្នុងមូលដ្ឋានជាក់ស្ដែង ដែលមានលំនៅដ្ឋានពិតប្រាកដ។ តារាងនេះ ក៏បង្ហាញផងដែរ ថាតើមានផ្ទះប៉ុន្មាន ដែលមានភ្លើងអគ្គិសនីប្រើ មានការបំភ្លឺដោយប្រើអាគុយ ហើយមានចំនួនប៉ុន្មានដែលមានទូរទស្សន៍ប្រើប្រាស់។*

| ប្រភេទលំនៅស្ថាន | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| ផ្ទះដំបូលប្រក់ស្បូវ ស្លឹក | 8 % | 7 % | 10 % | 1,809 ផ្ទះ |
| ផ្ទះដំបូលប្រក់សង្កសី ហ្វីប្រូស៊ីម៉ងត៍ | 82 % | 84 % | 81 % | 14,355 ផ្ទះ |
| ផ្ទះដំបូលក្បឿង | 3 % | 3 % | 3 % | 523 ផ្ទះ |
| ផ្ទះថ្មល្វែង(ច្រើនគ្រួសាររស់នៅ) | 3 % | 3 % | 3 % | 475 ផ្ទះ |
| ផ្ទះថ្ម ផ្ទះល្វែង(មួយគ្រួសាររស់នៅ) | 3 % | 3 % | 3 % | 543 ផ្ទះ |
| ផ្ទះភូមិគ្រឹះ | 0 % | 0 % | 0 % | 9 ផ្ទះ |

| ប្រភេទលំនៅស្ថាន | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | % | % | % | ចំនួន |
| ផ្ទះមានបណ្ដាញអគ្គីសនីប្រើប្រាស់ | 59 % | 60 % | 58 % | 10,250 ផ្ទះ |
| ផ្ទះដែលប្រើប្រាស់អំពូលបំភ្លឺដោយអាគុយ | 22 % | 23 % | 29 % | 5,058 ផ្ទះ |
| ផ្ទះមានទូរទស្សន៍ប្រើប្រាស់ | 67 % | 74 % | 78 % | 13,820 ផ្ទះ |

*សម្គាល់: គណនាធៀបនឹងចំនួនផ្ទះសរុប*

## ១.៣.២ គ្រួសាររស់នៅលើដីសាធារណៈ ឬគ្មានលំនៅស្ថានអចិន្ត្រៃយ៍

| ស្ថានភាពរស់នៅ | 2006 | 2007 | 2008 |
|---|---|---|---|
| គ្រួសារមានលំនៅដ្ឋានលើដីសាធារណៈ | 511 គ្រួសារ | 513 គ្រួសារ | 496 គ្រួសារ |
| គ្រួសារគ្មានលំនៅដ្ឋានអចិន្ត្រៃយ៍ | 18 នាក់ | 29 នាក់ | 15 នាក់ |

## ១.៣.៣ ភាគរយប្រជាជនមានលំនៅស្ថានទ្បេងទាត់តាមបណ្ដាសង្កាត់ ក្នុងឆ្នាំ២០០៨




*សម្គាល់: គណនាធៀបនឹងចំនួនផ្ទះសរុបតាមសង្កាត់នីមួយៗ*

## ១.៣.៤ ភាគរយផ្ទះដែលមានភ្លើងអគ្គីសនី អាគុយ និងទូរទស្សន៍តាម សង្កាត់ ក្នុងឆ្នាំ២០០៨




*សម្គាល់: គណនាធៀបនឹងចំនួនផ្ទះសរុបតាមសង្កាត់នីមួយៗ*

## ១.៣.៥ តារាងប្រភេទយាន/គ្រឿងយន្ត និងសមាមាត្រជាមួយចំនួនគ្រួសារក្នុងរយៈពេល៣ឆ្នាំកន្លងមក

*តារាងនេះ បង្ហាញពីចំនួនគ្រួសារ ធៀបនឹងយាន/គ្រឿងយន្ត មួយគ្រឿង។ កូឡោនចុងក្រោយបង្ហាញពីចំនួនសរុបនៃប្រភេទយាន/គ្រឿងយន្ត ក្នុងឆ្នាំ២០០៨។*

| បរិយាយ | 2006 | 2007 | 2008 | |
|---|---|---|---|---|
| | សមាមាត្រ | សមាមាត្រ | សមាមាត្រ | ចំនួន |
| កង់/កង់រ៉ឺម៉ក | 2 | 2 | 2 | 9,886 |
| រទេះគោ/រទេះសេះ | 92 | 104 | 40 | 480 |
| ម៉ូតូ/ម៉ូតូរ៉ឺម៉ក | 2 | 2 | 1 | 15,407 |
| ម៉ូតូកង់បី( ត្រីចក្រយានយន្ត) | 610 | 460 | 180 | 108 |
| មធ្យោបាយដឹកជញ្ជូនធុនធំ | | | | |
| ចំនួនរថយន្តសរុប | 17 | 18 | 21 | 938 |
| រថយន្តកែឆ្នៃក្នុងស្រុក | 220 | 151 | 155 | 125 |
| រថយន្តដឹកជញ្ជូនទំនិញ | 73 | 62 | 83 | 233 |
| រថយន្តឈ្នួលដឹកអ្នកដំណើរ | 113 | 592 | 373 | 52 |
| រថយន្តសំរាប់ប្រើប្រាស់ក្នុងគ្រួសារ | 31 | 33 | 37 | 528 |
| មធ្យោបាយភ្ជួរស្រែ | | | | |
| ត្រាក់ទ័រ( ភ្ជួរស្រែ) | 147 | 137 | 153 | 127 |
| គោយន្ត( ភ្ជួរស្រែ) | 13 | 14 | 11 | 1,763 |
| គ្រឿងយន្តគ្រឿងចក្រផ្សេងៗ | | | | |
| គ្រឿងយន្ត គ្រឿងចក្រផ្សេងៗ | 824 | 1,275 | 843 | 23 |
| មធ្យោបាយដឹកជញ្ជូនផ្លូវទឹក | | | | |
| ទូកចែវ/អុំ | 14 | 22 | 26 | 744 |
| | | | | |
| ទូកម៉ាស៊ីននិងកាណូតសរុប | 2,747 | 5,525 | 4,849 | 4 |
| ទូកម៉ាស៊ីននិងកាណូតសំរាប់នេសាទ | 3,297 | 5,525 | 4,849 | 4 |
| ទូកម៉ាស៊ីននិងកាណូតសំរាប់ដឹកអ្នកដំណើរ | N/A | N/A | N/A | 0 |
| ទូកម៉ាស៊ីននិងកាណូតសំរាប់ដឹកទំនិញ | 16,483 | N/A | N/A | 0 |

***សម្គាល់*** : សមាមាត្រគ្រួសារធៀប គឺជាផលចែករវាងចំនួនគ្រួសារសរុបក្នុងក្រុង ជាមួយចំនួនយាន/គ្រឿងយន្តសរុបតាមប្រភេទនិមួយៗ( ជួរដេក) ។
ដែលតួលេខនេះប្រើប្រាស់សំរាប់បញ្ជាក់ថា ប៉ុន្មានគ្រួសារ ទើបមានសម្ភារៈប្រភេទនោះ១គ្រឿង។

# ២ ផ្នែកសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ

## ២.១ ប្រភេទផ្លូវគិតជាម៉ែត្រ រយៈពេល៣ឆ្នាំកន្លង

| បរិយាយ | 2006 | 2007 | 2008 |
|---|---|---|---|
| ផ្លូវបេទីមីណឺ | 0 ម | 0 ម | 0 ម |
| ផ្លូវក្រាលកៅស៊ូ (DBST,MAKADAM) | 0 ម | 1,244 ម | 1,180 ម |
| ផ្លូវក្រាលបេតុង | 0 ម | 0 ម | 0 ម |
| | | | |
| ផ្លូវលំក្រាលក្រួសក្រហម ខ្សាច់ភ្នំ | 58,148 ម | 71,438 ម | 49,373 ម |
| ផ្លូវលំដីសរ ( លើកដីសរួច) | 16,909 ម | 17,727 ម | 14,158 ម |
| ផ្លូវលំធម្មតា ( មិនទាន់លើកដី) | 66,931 ម | 51,265 ម | 19,201 ម |

## ២.២ លូរំដោះទឹកកខ្វក់គិតជាម៉ែត្រ រយៈពេល៣ឆ្នាំកន្លង

| បរិយាយ | 2006 | 2007 | 2008 |
|---|---|---|---|
| **សរុបប្រវែងលូ មានអង្កត់ផ្ចិត ៣០-៥០ ស.ម(ថ្មី + ចាស់)** | 0 ម | 25 ម | 25 ម |
| ប្រវែងលូ អង្កត់ផ្ចិត ៣០-៥០ ស.ម-ត្រូវការសង់ថ្មី | 6 ម | 6 ម | 0 ម |
| ប្រវែងលូ អង្កត់ផ្ចិត ៣០-៥០ ស.ម-ត្រូវជួសជុល | 0 ម | 0 ម | 0 ម |
| **សរុបប្រវែងលូ មានអង្កត់ផ្ចិត ៦០-១០០ ស.ម(ថ្មី + ចាស់)** | 1,518 ម | 1,779 ម | 1,075 ម |
| ប្រវែងលូ អង្កត់ផ្ចិត ៦០-១០០ ស.ម-ត្រូវការសង់ថ្មី | 632 ម | 456 ម | 417 ម |
| ប្រវែងលូ អង្កត់ផ្ចិត ៦០-១០០ ស.ម-ត្រូវជួសជុល | 639 ម | 216 ម | 216 ម |
| **សរុបប្រវែងលូ អង្កត់ផ្ចិតធំជាង ១០០ ស.ម(ថ្មី + ចាស់)** | 0 ម | 0 ម | 0 ម |
| ប្រវែងលូ អង្កត់ផ្ចិតលើស ១០០ ស.ម-ត្រូវការសង់ថ្មី | 0 ម | 0 ម | 0 ម |
| ប្រវែងលូ អង្កត់ផ្ចិតលើស១០០ ស.ម-ត្រូវជួសជុល | 0 ម | 0 ម | 0 ម |

## ២.៣ ប្រភេទសំណង់រំដោះទឹក និងស្ពាន

| ប្រភេទសំណង់ | 2006 | | 2007 | | 2008 | |
|---|---|---|---|---|---|---|
| | កន្លែង | ប្រវែង | កន្លែង | ប្រវែង | កន្លែង | ប្រវែង |
| លូទោល | 123 | 1,422 ម | 105 | 749 ម | 99 | 707 ម |
| លូភ្លោះ | 7 | 49 ម | 5 | 53 ម | 5 | 41 ម |
| លូទ្រីប ( លូជ្រុង) | 9 | 69 ម | 7 | 65 ម | 3 | 14 ម |
| ស្ពានឈើ | 3 | 125 ម | 2 | 29 ម | 2 | 29 ម |
| ស្ពានបេតុង | 14 | 89 ម | 13 | 350 ម | 14 | 89 ម |
| ស្ពានដែក | 0 | 0 ម | 1 | 20 ម | 1 | 40 ម |
| សំណង់បង្ហូរទឹក | 4 | 40 ម | 4 | 45 ម | 3 | 20 ម |

## ២.៤ សេវាកម្មនានាក្នុងក្រុង

| បរិយាយ | ចំនួនកន្លែងតាមបណ្តាឆ្នាំ | | |
|---|---|---|---|
| | 2006 | 2007 | 2008 |
| **សាធារណៈ** | | | |
| ចំនួនកន្លែងម៉ាស៊ីនភ្លើងអគ្គិសនី | 1 | 8 | 9 |
| ចំនួនកន្លែងគ្លីនិចសុខភាព | 10 | 6 | 11 |
| **ឯកជន** | | | |
| ចំនួនកន្លែងជួសជុលកង់ ម៉ូតូ | 56 | 59 | 59 |
| ចំនួនកន្លែងជួសជុលគ្រឿងយន្តនិងឧបករណ៍កសិកម្ម | 42 | 116 | 54 |
| ចំនួនកន្លែងជួសជុលគ្រឿងអេឡិចត្រូនិក | 25 | 30 | 36 |
| ចំនួនកន្លែងសាកបញ្ចូលភ្លើងអាគុយ | 36 | 37 | 43 |
| ចំនួនកន្លែងសិប្បកម្មធ្វើគ្រឿងសង្ហារឹមអំពីឈើនិងអនុផលព្រៃឈើ | 17 | 17 | 17 |
| ចំនួនកន្លែងសិប្បកម្ម ( ផ្សេងៗក្រៅពីគ្រឿងសង្ហារឹម ) | 14 | 15 | 14 |
| ចំនួនសេវាកម្មខ្នាតតូច ( កាត់សក់ បំរើទូរស័ព្ទ ម៉ាស្សា ការ៉ាអូខេ) | 79 | 76 | 95 |
| ចំនួនអាជីវកម្មខ្នាតតូច ( លក់បាយ គ្រឿងទេស ភេសជ្ជៈ ...... ) | 550 | 540 | 537 |
| ម៉ាស៊ីនកិនស្រូវខ្នាតតូច | 20 | 20 | 31 |
| ម៉ាស៊ីនកិនស្រូវខ្នាតមធ្យម និងធំ | 16 | 15 | 17 |
| ចំនួនផ្សារខ្នាតធំ | 3 | 3 | 4 |
| ចំនួនផ្សារខ្នាតតូច | 2 | 1 | 2 |
| ចំនួនកន្លែងសិប្បកម្មបិតស្រា | 17 | 22 | 29 |
| ចំនួនឱសថស្ថាន និងឱសថស្ថានរង | 19 | 11 | 19 |
| ចំនួនសណ្ឋាគារ | 5 | 7 | 5 |
| ចំនួនផ្ទះសំណាក់ | 14 | 19 | 13 |
| ចំនួនភោជនីយដ្ឋាន | 11 | 8 | 9 |
| ចំនួនស្ថានីយ៍ប្រេងឥន្ធនៈ | 7 | 13 | 13 |

## ២.៥ កសិកម្ម

### ២.៥.១ ការបង្កបង្កើនផលស្រូវក្នុងស្រុក រយៈពេល៣ឆ្នាំ

| បរិយាយ | 2006 | 2007 | 2008 |
|---|---|---|---|
| ផ្ទៃដីបង្កបង្កើនផលស្រូវប្រាំង | 0 ហ.ត | 0 ហ.ត | 755 ហ.ត |
| ផ្ទៃដីដាំដុះជាក់ស្តែង | 0 ហ.ត | 0 ហ.ត | 755 ហ.ត |
| % ផ្ទៃដីស្រូវប្រាំងបានដាំ | -% | -% | 100% |
| បរិមាណផលស្រូវប្រាំងសរុប | - តោន | - តោន | 1,510 តោន |
| ទិន្នផលជាមធ្យម | - ត/ហ.ត | - ត/ហ.ត | 2.0 ត/ហ.ត |
| | | | |
| ផ្ទៃដីបង្កបង្កើនផលស្រូវវស្សា | 15,800 ហ.ត | 15,818 ហ.ត | 20,661 ហ.ត |

| បរិយាយ | 2006 | 2007 | 2008 |
|---|---|---|---|
| ផ្ទៃដីដាំដុះជាក់ស្តែង | 15,800 ហ.ត | 15,229 ហ.ត | 20,582 ហ.ត |
| %ផ្ទៃដីស្រូវវស្សាបានដាំ | 100 % | 96% | 100% |
| បរិមាណផលស្រូវវស្សាសរុប | 21,894.20 តោន | 18,274.80 តោន | 24,441.01 តោន |
| ទិន្នផលជាមធ្យម | 1.4 ត/ហ.ត | 1.2 ត/ហ.ត | 1.2 ត/ហ.ត |
| | | | |
| ផ្ទៃដីបង្កបង្កើនផលស្រូវបង្កើនរដូវ | 0 ហ.ត | 0 ហ.ត | 4,186 ហ.ត |
| បរិមាណផលស្រូវបង្កើនរដូវសរុប | - តោន | - តោន | 6,279 តោន |
| ទិន្នផលជាមធ្យម | - ត/ហ.ត | - ត/ហ.ត | 1.5 ត/ហ.ត |
| | | | |
| ផ្ទៃដីស្រូវចំការ | 0 ហ.ត | 0 ហ.ត | 0 ហ.ត |
| បរិមាណផលស្រូវចំការសរុប | - តោន | - តោន | - តោន |
| ទិន្នផលជាមធ្យម | - ត/ហ.ត | - ត/ហ.ត | - ត/ហ.ត |

## ២.៥.២ ទិន្នផលស្រូវវស្សា និងប្រាំងប៉ាន់ស្មានជាមធ្យមគិតជាតោន តាមសង្កាត់ក្នុងឆ្នាំ២០០៨




## ២.៥.៣ ភាគរយផ្ទៃស្រូវប្រាំង និងស្រូវវស្សាបានដាំដុះជាក់ស្តែងតាមសង្កាត់ ក្នុងឆ្នាំ២០០៨



## ២.៥.៤ ទិន្នផលស្រូវបង្កើនរដូវប៉ាន់ស្មានតាមសង្កាត់ ក្នុងឆ្នាំ២០០៨




## ២.៥.៥ ទិន្នផលស្រូវចំការប៉ាន់ស្មានតាមសង្កាត់ ឆ្នាំ២០០៨

គ្មានទិន្នផលស្រូវចំការនៅក្នុងក្រុងនេះ ក្នុងឆ្នាំ២០០៨ទេ

## ២.៥.៦ ផ្ទៃដីស្រោចស្រពនៅរដូវវស្សារយៈពេល៣ឆ្នាំកន្លង

| បរិយាយ | | 2006 | 2007 | 2008 | |
|---|---|---|---|---|---|
| | | % | % | % | ចំនួន |
| សរុបផ្ទៃដីស្រូវពឹងទឹកភ្លៀងទាំងស្រុង | | 100 | 100 | 100 | 20,582 ហ.ត |
| | | | | | |
| សរុបផ្ទៃដីដែលបានបញ្ចូលទឹកបង្ក្រប់ និងសម្រាប់ផ្ទៃដីឆ្នាំ២០០៨ | | 0 | 0 | 0 | 0 ហ.ត |
| ក្នុងនោះ ពីប្រភព: | ប្រឡាយ-ទំនប់ | - | - | - | 0 ហ.ត |
| | ទន្លេ ស្ទឹង បឹង អូរ ត្រពាំង | - | - | - | 0 ហ.ត |
